# សង្គ្រាមទាន់ហន់...

L'engrenage de la guerre

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី២៩ មិថុនា ២០០៦

...តែមួយអាទិត្យប៉ុណ្ណោះសោះ បន្ទាប់ពីការទម្លាក់សម្ដេចសីហនុ, សង្គ្រាមក៏បានដល់មាត់ទ្វារនៃកម្ពុជា ដែលកំពុងតែដេកលក់ ។ សង្គ្រាមនេះផាយផាត់មកដល់លឿនពេក, ទាន់ហន់ពេក ដែលវាមិនអាចកើតឡើងដោយឯងៗសោះ ។ ល្បឿននៃសង្គ្រាមដែលរសាត់មកឆាបឆេះនៅកម្ពុជា វារហ័សដូចផ្លេកបន្ទោរ... មិនគួរឲ្យយល់បានសោះ បើឧបមាដូចគំនិតរបស់អ្នកផង ដែលយល់ថា ទោសកំហុសនៃសង្គ្រាម វាត្រូវធ្លាក់ទៅលើឧត្តមសេនិយលន់-នល់ (ការកាប់សម្លាប់យួន) និងទៅលើអ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈ (ការទម្លាក់ស្ដេចសីហនុ) ។

ប៉ុន្តែសង្គ្រាមនេះ គេអាចយល់បានច្បាស់លាស់ល្អពេកណាស់, ហើយក៏វាមានលក្ខណៈជាក់ស្ដែងទៀតផង (អំពីនរណាជាអ្នកដើមភ្លើង)... បើឧបមាថា វាកើតឡើងដោយឆន្ទៈរបស់វៀតណាមខាងជើងតែមួយប៉ុណ្ណោះ ។ គឺបានសេចក្ដីថា សង្គ្រាមនេះមានពួកយួនជាអ្នកចង់បាន ។ គឺបានសេចក្ដីថា សង្គ្រាមស្រុកខ្មែរបានឋិតនៅជាគំរោងរៀបចំរួចស្រេចបាច់ទៅហើយ នៅក្នុងពាក្យបណ្ដាំរបស់ហូ-ជីមិញ ។ ដោយហេតុថា សង្គ្រាមបានបោកមកដល់ដោយល្បឿនយ៉ាងលឿន ប្រហែលនឹងអស្សុរពារ៍ដូចនេះ ភ្លាមបន្ទាប់ពីថ្ងៃទី១៨មីនា១៩៧០, គឺមកពីថ្ងៃនេះបានត្រូវជ្រើសរើសរួចទៅហើយដោយជនជាតិយួន ។ សង្គ្រាមមិនដែលកើតឡើងដោយចៃដន្យនោះទេ ។ ពួកកុម្មុយនិស្តវៀតណាម ជាជនដែលមានបញ្ញាញាណវ័យឆ្លាត ហើយពូកែខាងគន់គូរទុកជាមុនណាស់, ពួកគេមិនបានទុកឲ្យមានព្រេងសំណាងហេងស៊ុយទេ ។ កាលនោះពុំទាន់មានអាមេរិកាំងនៅស្រុកខ្មែរនៅឡើយទេ... ហើយបើពួកនេះថ្ងៃក្រោយមកត្រូវរត់ចូលទាំងប្រផាប់ប្រផីង ចូលមកក្នុងទឹកដីកម្ពុជា ដែលកំពុងត្រូវយួនយៀកកុងឡោមព័ទ្ធរុំស្ទួតអស់ទៅហើយ... នោះគឺបណ្ដាលមកពីលោកប្រធានាធិបតីនិចសុន បានត្រូវធ្លាក់ចូលអន្ទាក់របស់គេ ។ ហើយនៅក្នុងពេលជាមួយគ្នា ដែលទាហានអាមេរិកាំងរត់ស្រចូលមកធ្វើអន្តរាគមន៍ក្នុងដែនដីខ្មែរ... ពួកអ្នកកាសែតទាំងអស់ក៏បានបំភ័ន្តសតិស្មារតី ។ ម៉្យាងវិញទៀត ពួកអាមេរិកាំងកំពុងតែតម្រង់រកច្រកចេញពីឥណ្ឌូចិនប៉ុណ្ណោះ... នៅពេលដែលយួនបានសំរេចជ្រើសយ-

កដំណោះស្រាយយោធារួចស្រេចទៅហើយនៅកម្ពុជា ៖ ពោលគឺការធ្វើសឹកសង្គ្រាម ។ គឺបានសេចក្ដីថា ពួកវៀតណាមបានធ្វើការសំរេចពីយូរយារណាស់មកហើយ ពុំមែនចេះតែចូលមកដើរផ្សងព្រេងទាំងល្ងីល្ងើពកថ្វាស (ដូចអាគាំង) នោះទេ !

ដើម្បីអាចធ្វើសឹកសង្គ្រាមនៅកម្ពុជាបាន...គេត្រូវមានកត្តាពីរយ៉ាងដូចក្នុងផ្នែកគណិតសាស្ត្រអីចឹងឯង គឺកត្តាចាំបាច់និងកត្តាគ្រប់គ្រាន់ ។ ពួកវៀតណាមគឺជាកត្តាចាំបាច់ ដោយហេតុថាពួកគេមានកងកម្លាំងសំរាប់វាយប្រហាររហូតដល់២០០,០០០នាក់នៅប្រទេសកម្ពុជា ។ ក៏ប៉ុន្តែពួកគេក៏មានកត្តាគ្រប់គ្រាន់នៅក្នុងដៃផងដែរ ៖ គឺសម្ដេចសីហនុ, មេដំបែនៃកុម្មុយនិស្តអាស៊ី ប្រកបដោយព្រះកិត្តិនាមអន្តរជាតិ និងល្បិចកល១០០ជំពូក ។ សម្ដេចសីហនុ មិនមែនត្រឹមតែជាអ្នកលេងល្បែងឲ្យខ្មាំងយួនឈ្នះតែប៉ុណ្ណោះទេ... ប៉ុន្តែគាត់ក៏ជាភ្នាក់ងារ, ជាជនបំរើផលប្រយោជន៍វៀត-ណាមកុម្មុយនិស្តដោយដឹងខ្លួនផងដែរ (Un agent conscient) (តាំងពីកាលណាមក... ខ្ញុំមិនអាចស្មានបានទេ... ប្រហែលតាំងពីព្រះរាជបូជនិយកិច្ចទាមទារឯករាជ្យនៃឆ្នាំ១៩៥៣... ប៉ុន្តែរឿងនេះ គឺសំរាប់សរសេរសៀវភៅមួយទៀត) ។ រហូតដល់ចុងចប់សម្ដេចបានធ្វើឲ្យជនជាតិខ្មែរខ្វះគ្រឿងអាវុធការពារខ្លួន ។ ដោយត្រូវដងត្រូវផ្លែជាមួយផាំ-យ៉ាំងដុង សម្ដេចបានបង្វិលសភាពការណ៍ប៉ីភ័ន្តស្មារតី តាំងពីរដ្ឋាភិបាលស្រោចស្រង់ជាតិ... ពួកមន្ត្រីជាន់ខ្ពស់ និងពួកអ្នកចេះដឹងទាំងអស់នៅកម្ពុជាឲ្យពួកគេរមៀលធ្លាក់ជាចំណីនៃភ្លើងសង្គ្រាម ។ រហូតដល់ចុងចប់ សម្ដេចសីហនុបានជួយចូកជួយចែវ ឲ្យជនជាតិខ្មែរធ្លាក់ចូលក្នុងសំណាញ់យួន ប្រហែលគ្នានឹងសត្វត្រីសំរាប់យកទៅចៀនបរិភោគ ។ ប្រហែលជាលន់-នល់ក៏ចង់ក្បត់សីហនុដែរ ប្រហែលលោកឧត្តមសេនីយ៍ក៏មានបំណងចង់ដេញយួនឲ្យអស់ពីស្រុកខ្មែរផងដែរ... ប៉ុន្តែរឿងចំណង់ទាំងអស់នេះ បានឋិតនៅត្រឹមតែជាចំណង់តែប៉ុណ្ណោះ ឬក៏ត្រឹមតែបន់ព្រះសំពះទេព្ដា (Wishfull thinking) ។ រឿងទង្វើទាំងប៉ុន្មាន បង្កើតឡើងជាព្រឹត្តិការណ៍ ជាភ្លៀងខ្យល់ ជាសឹកសង្គ្រាម, គឺផាំ-យ៉ាំងដុងនិងសីហនុជាអ្នកចំណាត់ការជំនួសទាំងអស់ ។

❑

❑ ❑

តទៅនេះជាអត្ថបទមួយចុះផ្សាយនៅ «Réalités Cambodgiennes» ថ្ងៃទី៤ មេសា ១៩៧០ ៖

«ការប្រែប្រួលត្រឡប់ត្រឡិនរបស់នរោត្តម-សីហនុ

«នរោត្តម-សីហនុ នៅពេលដែលចាកចេញពីទីក្រុងប៉ារីស បានប្រកាសថា ទ្រង់នឹងទៅស្នើចំពោះម៉ូស្គូនិងប៉េកាំង ឲ្យធ្វើការសម្ពាធទៅលើមិត្តភក្តិរបស់ពួកគេ គឺពួកយៀកណាម ឲ្យដើរចាកចេញពីទឹកដីខ្មែរ, ក៏ស្រាប់តែមានការប្រែប្រួលត្រឡប់ត្រឡិនមួយរំពេច ដោយបានដឹង មុននឹងចាកចេញពីសហភាពសូវៀតឆ្ពោះទៅប្រ-

ទេសចិន អំពីការធ្លាក់បុណ្យរបស់ទ្រង់ ដែលទ្រង់បានចោទយ៉ាងប្រញាប់ថា ជាទង្វើរបស់ «ពួកក្រុមស្តាំនិយម, ពួកប្រតិកិរិយា» ដែលគាំទ្រដោយសហរដ្ឋអាមេរិក និងសេអ៊ីអា ។

«បន្ទាប់ពីបានសន្ទនាយ៉ាងយូរជាមួយនឹងជូ-អេនឡាយ និងផាំ-យ៉ាំងដុង, ទ្រង់បានធ្វើសេចក្តីថ្លែងការណ៍អំពាវនាវឲ្យមានការងើបឡើងបះបោរប្រឆាំងនឹងរដ្ឋាភិបាលស្របច្បាប់នៃប្រទេសរបស់ខ្លួនឯង ហើយទ្រង់ក៏បានផ្ញើទូរលេខ ទៅគាំទ្រលោកង្វៀង-ហ៊ូថ ប្រធាននៃរណសិរ្សរំដោះវៀតណាមខាងត្បូង និងលោកង្វៀង-គាន់ផាត់ ប្រធានរដ្ឋាភិបាលយៀកកុង ។ យោងតាមទីភ្នាក់ងារព័ត៌មាន«ចិនថ្មី» (ដែលទ្រង់បានរិះគន់យ៉ាងខ្លាំង កាលពីពីរឆ្នាំកន្លងទៅ) ទ្រង់បានថ្លែងថា ទ្រង់មានសេចក្តីត្រេកអរណាស់ ដោយបានបោះបង់ចោល«អព្យាក្រឹត្យភាពអសកម្ម» (Neutralité passive) (ដោយប្រើគុណនាមបែបនេះ គឺជាសេចក្តីសារភាពអស្ចារ្យណាស់) ។ ទ្រង់បានបញ្ជាក់ដូចនេះថា ៖ «ពួកអ្នកស្នេហាជាតិជឿនលឿន, ប្រឆាំងនឹងលទ្ធិហ្វាស៊ីស្ត ហើយនិងចក្រពត្តិនិយម មានសេចក្តីត្រេកអរណាស់ ដោយបានឃើញថា «រដ្ឋប្រហារ» (sic) នៅភ្នំពេញបានបង្ខំពួកគេ ឲ្យប្រើ«កងកម្លាំងយោធា»ក្នុងការតស៊ូ, ឲ្យបោះបង់ចោលអព្យាក្រឹត្យភាពអសកម្ម ព្រមទាំងឲ្យទៅចូលរួបរួមជាមួយនឹងពួកប្រជាជន ដែលប្រយុទ្ធដោយគ្រឿងអាវុធនិងដោយដៃ តទល់នឹងចក្រពត្តិនិយម ហើយនិងពួកជនក្បត់» ។

«ចូលរួបរួមក្នុងការប្រយុទ្ធកម្លាំងទ័ពតទល់នឹងចក្រពត្តិនិយម គឺជាការលះបង់ចោលនូវអព្យាក្រឹត្យភាព «សកម្មក្តី ឬអសកម្មក្តី» ដើម្បីឆ្លងទៅចូលក្នុងជួរខាងម្ខាង ។ ហើយនៅក្នុងប្រការនរោត្តម-សីហនុ គឺជាការរត់ចូលទៅក្នុងជួររបស់យៀកមិញ, យៀកកុង, ប៉ាថេតឡាវ និង«រណសិរ្សស្នេហាជាតិថៃ»។ ម៉្លោះហើយ ក៏ជាការឆ្លងកាត់ចូលទៅក្នុងជួរ ដែលថ្មីៗនេះនៅឡើយ សីហនុប្រសិទ្ធិនាមថាជា «ចក្រពត្តិនិយមម្ខាងទៀត»... ពោលគឺពួកកុម្មុយនិស្តអាស៊ី ។ គឺជាការណែនាំជាតិខ្មែរ ឲ្យប្រយុទ្ធតស៊ូដើម្បីបំរើផលប្រយោជន៍មួយ ដែលមិនមែនជាផលប្រយោជន៍របស់ខ្មែរ» ។

«នៅពេលដែលរដ្ឋាភិបាលលន់-នល់ (<u>កកន</u> ៖ គេសង្កេតឃើញថា នៅពេលដែលសីហនុកេណ្ឌទ័ពយៀកកុង មកវាយប្រហារស្រុកខ្មែរទៅហើយ... លន់-នល់នៅតែជារដ្ឋាភិបាលអសកម្ម ត្រូវគេសម្លាប់ហើយឥតមានតដៃ... គឺជារដ្ឋាភិបាលរងកម្ម រងអំពើរបស់យួនឈ្លានពាន)... រដ្ឋាភិបាលលន់-នល់នៅតែប្រកាន់យកគោលការណ៍ឯករាជ្យ, អព្យាក្រឹត្យ, បូរណភាពទឹកដីនៃប្រទេសជាតិ... មិនគឺជាការគួរឲ្យសោកស្តាយទេឬ ដែលអតីតប្រមុខរដ្ឋ ដែលបានអះអាងក្នុងពេលថ្មីៗនេះថា ទ្រង់នឹងសុខចិត្តលះបង់ដំណាក់ឈាមចុងក្រោយ ដើម្បីការពារគោលការណ៍ទាំងនេះ បែរជាចោទប្រកាន់ពួកសហការីចាស់របស់ទ្រង់ ថាជា«ពួកជនក្បត់» ព្រោះតែពួកគេនៅស្មោះត្រង់នឹងការបង្ហាត់បង្រៀនដ៏ល្អរបស់ទ្រង់, ហើយបែរទៅជាចូលដៃជា

មួយនឹងខ្មាំងសត្រូវរបស់ប្រជាជាតិខ្លួនឯង ដែលឈាមកំពុងតែហូរ ព្រមទាំងទៅជួយសកម្មភាពរបស់ខ្មាំងទាំងនេះ ក្នុងប្រការលេបត្របាក់ទឹកដីរបស់ជាតិខ្លួនឯងទៅវិញ... ហើយរឿងទាំងអស់នេះ ក៏ព្រោះតែបញ្ហាផ្ទាល់ខ្លួនដែលបានខ្វាចឆ្អួតនិងប៉ះទង្គិចយ៉ាងជ្រៅ ដល់«អំនួតរបស់ទ្រង់» (កកន ៖ ក្រៅពីការបញ្ជាក់អំពីសេចក្ដីស្មោះត្រង់របស់ខ្លួន គេឃើញថារដ្ឋាភិបាលលន់-នល់ ឥតមានវត្ថុអ្វីសោះសំរាប់ទប់ទល់នឹងអំពើក្បត់របស់ស្ដេចសីហនុ !!) ។

❑

❑ ❑

⋆⋆⋆ ទស្សនាវដ្ដីរបស់រដ្ឋាភិបាល «Réalités Cambogiennes» នៃថ្ងៃទី៤មេសា១៩៧០ដដែល បានចុះផ្សាយអត្ថបទមួយទៀត ដែលបង្ហាញពីគោលជំហររបស់អ្នកអង្គម្ចាស់ស៊ីសុវត្ថិ-សិរិមតៈបន្ទាប់ពីរដ្ឋប្រហារ ៖

«សករាជមួយថ្មីបានកើតឡើងហើយសំរាប់អ្នកទាំងអស់

អ្នកអង្គម្ចាស់សិរិមតៈ ឧបនាយករដ្ឋមន្ត្រីទី១ បានចេញផ្សាយសារាចរមួយច្បាប់ សំរាប់ភ្នាក់ងាររាជការទូទាំងប្រទេស ។ យើងសូមដកស្រង់ចំណុចសំខាន់ៗខ្លះពីអត្ថបទសារាចរនេះ ដែលមានសេចក្ដីដូចតទៅ ៖

«បងប្អូនរួមជាតិជាទីស្នេហា,

ទំព័រមួយថ្មីនៃប្រវត្តិសាស្ត្រប្រទេសជាតិយើង បានបើកឡើងហើយ

«ថ្ងៃដ៏ល្អប្រសើរ, ទិវានៃការរំដោះផ្លូវគំនិត និងដួងចិត្ត ដែលបងប្អូនទាំងអស់គ្នាបានរង់ចាំ នៅទីបំផុតក៏បានរសាត់មកដល់ គឺថ្ងៃទី១៨ មីនា ១៩៧០ នៅម៉ោង១៣:០០ (ម៉ោង១រសៀល) ។

« សករាជនៃអយុត្តិធម៌, នៃការជិះជាន់សង្កត់សង្កិន, នៃកង្វះសេចក្ដីស្ងប់ស្ងាត់នៅក្នុងសតិអារម្មណ៍, នៃការប្រកាន់បក្សពួកគ្រប់បែបយ៉ាង, នៃអនាធិបតេយ្យដែលបណ្ដាលមកពីការប្រើអំណាចផ្ដាច់ការ ពោលអំណាចសក្តិភូមិសម្បូណ៌ាញាសិទ្ធិរាជរបស់នរោត្តម-សីហនុ បានត្រូវចប់ត្រឹមនេះហើយ ។

«សករាជថ្មីកំពុងរង់ចាំទទួលយើងទាំងអស់គ្នា ៖ គឺសករាជនៃសេចក្ដីសង្ឃឹម, នៃយុត្តិធម៌, នៃការវិលត្រឡប់មករបៀបរៀបរយឥតខ្ចោះនៃរដ្ឋបាល និងការគោរពច្បាប់ ពីសំណាក់ប្រជាពលរដ្ឋទាំងអស់នៅក្នុងប្រទេសជាតិ ។

«កំហុសជាច្រើនដ៏ធ្ងន់ធ្ងរ ជាកំហុសផ្ទាល់ខ្លួនផង ដែលនរោត្តម-សីហនុបានប្រព្រឹត្ត បានណែនាំប្រទេសជាតិយើងមកដល់មាត់ជ្រោះអន្តរាយ ដូចជាអធិបតេយ្យ, លទ្ធភាពនៃការផ្ទុះសង្គ្រាមស៊ីវិល, ការរាតត្បាតបន្តិចម្ដងៗចូលមកក្នុងទឹកដីនៃប្រទេសជាតិ ពីសំណាក់ខ្មាំងសត្រូវស្ទួរពូជ... រឿងទាំងនេះត្រូវបានអ្នកទាំងអស់ដឹងនិងជ្រាបជាយូរមករួចទៅហើយ ។

«បងប្អូនរួមជាតិជាទីស្នេហា, ដោយបងប្អូនជាអ្នកចេះដឹង ដែលធានាអនាគត

នៃប្រទេសជាតិជាទីស្រឡាញ់របស់យើង (<u>កកន</u> ៖ គេអាចមើលឃើញថា ទ្រង់សិរិមត:និយាយទៅកាន់អ្នករាជការ ហើយនិងអ្នកចេះដឹងប៉ុណ្ណោះ ប៉ុន្តែមិនបាននិយាយទៅកាន់ប្រជារាស្ត្រតូចតាចស្រទាប់ក្រោម ដែលជាភាគច្រើនលើសលប់នោះទេ នេះជាចំណុចខ្សោយមួយ ដែលអនុញ្ញាតឲ្យស្តេចសីហនុ ឃោសនាប្រជាភិថុតិជាមួយពួកខ្មែរក្រហម ជាន់កទ្រង់សិរិមត:មិនឲ្យរើបំរះរួច)... បងប្អូនបានរងទទួលអំពើនៃទង្វើខុសទាំងនេះគ្រប់ៗគ្នា ហើយបងប្អូនក៏បានមូលមតិដាក់ទោសគ្រប់ៗគ្នាផងដែរ ពីព្រោះវាជាលទ្ធផលនៃអំណាចផ្តាច់ការដ៏សែនឃោរឃៅរបស់នរោត្តម-សីហនុ ។

«ខ្ញុំឆ្លៀតឱកាសពេលនេះ ដើម្បីធ្វើសេចក្តីថ្លែងសរសើរ ចំពោះគំនិតលះបង់និងការស្រឡាញ់វិន័យរបស់បងប្អូន ។

«ព្រឹត្តិការណ៍ក្នុងប៉ុន្មានថ្ងៃចុងក្រោយនេះ ដែលបានណែនាំឲ្យមានការទម្លាក់ស្តេចផ្តាច់ការ ពីមុខតំណែងព្រះប្រមុខរដ្ឋ ពីសំណាក់សភាទាំងពីររបស់យើង វាគ្រាន់តែជាលទ្ធផលនៃការផ្ទុះកំហឹង ដែលប្រជាពលរដ្ឋទាំងមូល បានប្រឹងអត់ទ្រាំជាយូរយារណាស់មកហើយ ។ យើងមិនបាច់ពន្យល់បងប្អូន អំពីមូលហេតុនៃការទម្លាក់នេះទេ... ពីព្រោះបងប្អូនក៏បានយល់ច្បាស់លាស់រួចស្រេចបាច់អស់ទៅហើយ អំពីខ្លឹមសារនិងផលប្រយោជន៍នៃទង្វើរបស់ពួកក្រុមសភាជាប់ឆ្នោតទាំងនេះ ។

«រដ្ឋាភិបាលស្រោចស្រង់ជាតិ ដែលត្រូវប្រឈមនឹងបញ្ហាគ្រប់ជំពូក ទោះផ្ទៃក្នុងក្តី ទោះមកពីក្រៅក្តី មានសេចក្តីសង្ឃឹមទុកជាមុន ទៅលើសេចក្តីស្នេហាជាតិឥតខ្ចះខាតនៃបងប្អូន (<u>កកន</u> ៖ «បងប្អូនរួមជាតិ»ទាំងនេះ ទាំងក្នុងរដ្ឋាភិបាល និងក្នុងរដ្ឋសភាភាគច្រើន ដោយរាប់ទាំងអ្នកអង្គម្ចាស់សុិសុវត្ថិ-សិរិមត:ផងដែរ... ថ្ងៃក្រោយទៅ បានវិលត្រឡប់ទៅរកស្តេចសីហនុវិញសឹងទាំងអស់គ្នា... គឺវាហាក់ដូចជាថារដ្ឋប្រហារថ្ងៃទី១៨ មីនា ១៩៧០ ជារឿងល្ខោនកំប្លុកកំប្លែង រវាងស្តេចសីហនុ ហើយនិងរដ្ឋាភិបាលស្រោចស្រង់ជាតិទៅវិញសោះ... រឿងកំប្លុកកំប្លែងមួយ ដែលបណ្តាលឲ្យជនខ្មែរស្លាប់អស់៣លាននាក់ !!!)... រដ្ឋាភិបាលស្រោចស្រង់ជាតិមានសេចក្តីសង្ឃឹមទៅលើ ការប្រកាន់យកករណិយកិច្ចនិងវិន័យជាធំ, ទៅលើបញ្ញាស្មារតីរបស់បងប្អូន ដើម្បីជួយស្តារប្រទេសជាតិ ឲ្យចេញផុតពីសភាពការណ៍បច្ចុប្បន្ន ដែលជាមរតកអភ័ព្វបន្សល់ទុកដោយនរោត្តម-សីហនុ ។ ដោយមានជំនួយពីបងប្អូនទាំងអស់គ្នា, យើងច្បាស់ជាធ្វើឲ្យកិច្ចការដ៏ធំធេងនេះ បានសំរេចជោគជ័យជាពុំខាន

«បងប្អូនណាដែលបានទទួលរងអំពើអយុត្តិធម៌ និងការប្រមាថគ្រប់បែបយ៉ាងនៅក្រោមអំណាចផ្តាច់ការរបស់នរោត្តម-សីហនុ នឹងមានសេចក្តីរំពឹងមកលើបច្ចុប្បន្នរដ្ឋាភិបាលស្រោចស្រង់ជាតិ ដើម្បីធ្វើសំណងសិទ្ធិ ដែលគេបានជាន់ឈ្លីត្រឡប់ជូនបងប្អូនវិញ ។

«នៅក្នុងក្របខ័ណ្ឌនៃការបោសសំអាតកំចាត់អំពើពុករលួយជាទូទៅនៃរដ្ឋការ

របស់យើង ហើយនៅក្នុងគោលប្រាថ្នា បង្ខំឲ្យប្រជាជាតិយើងមានដំណើរជឿនលឿនទៅមុខ រដ្ឋាភិបាលស្រោចស្រង់ជាតិ ដោយលះបង់គ្មានសល់ នូវគំនិតប្រកាន់បក្សពួក ច្បាស់ជានឹងអាចចែករង្វាន់ដល់ពួកអ្នកបំរើជាតិពិតប្រាកដ ព្រមទាំងគ្មានការញញើតនឹងធ្វើការផ្តន្ទាទោស ស្របតាមលក្ខណៈច្បាប់ទៅលើពួកក្រុមជនពុករលួយ ។

«បាវចនានៅពេលនេះ សំរាប់ភ្នាក់ងាររាជការទាំងអស់គឺ «ការបំរើជាតិដ៏ស្មោះសរ និងការបំរើជាតិដ៏ល្អ» ។

«សូមអរគុណបងប្អូនទាំងអស់គ្នា ហើយសូមឲ្យមានសេចក្តីសង្ឃឹម» ។

⋆⋆⋆ យោងតាមអត្ថបទខាងលើនេះ ខ្ញុំសម្លឹងឃើញថា អ្នកអង្គម្ចាស់ស៊ីសុវត្ថិ សិរិមតៈមានសេចក្តីរំពឹងទាំងស្រុង កាលសម័យនោះ ទៅលើមេឃលើផ្កាយ, ទៅលើ«ការរំដោះផ្លូវគំនិតនិងដួងចិត្ត» ។ ទ្រង់មានការភ្ញាក់ផ្អើលខ្លាំងណាស់ សឹងតែមិនជឿលើខ្លួនឯង អំពីការដួលរលំរបស់សម្តេចសីហនុ ។ ទ្រង់មិនបានសង្កេតឃើញ អំពីសភាពការណ៍ដ៏ធ្ងន់ធ្ងរនៃប្រទេសជាតិ... ហើយក៏បានប្រកាសពី«សករាជមួយថ្មី» នៅចំពេលជាមួយគ្នា ដែលសម្តេចសីហនុកំពុងតែពន្យុះជនជាតិយួន ឲ្យចូលមកអារកជនជាតិខ្មែរនៅគ្រប់ច្រកល្ហក ឲ្យវាយប្រហារសម្លាប់រដ្ឋាភិបាលនិងប្រជាជាតិរបស់ទ្រង់ឲ្យក្សិណក្ស័យ ។ ក្នុងករណីនេះ ទ្រង់សិរិមតៈក៏ដូចតែលោកលន់នល់ គឺជាជនឥតវិញ្ញាណ (inconscient) ដែលមិនបានដឹងអំពីគ្រោះថ្នាក់ដល់ស្លាប់ដែលកំពុងតែគ្របសង្កត់មកលើកម្ពុជា ។

ទ្រង់សិរិមតៈនៅតែមិនទាន់អស់ចិត្តនៅឡើយអំពី «សណ្តាប់ធ្នាប់និងរបៀបរៀបរយឥតមានផ្តាំផ្តង» នៃក្រសួងរដ្ឋការរបស់ទ្រង់ ។ ប៉ុន្តែគេអាចសម្លឹងមើលឃើញការរសាត់ផាត់ចេញ ពីក្នុងអត្ថបទរបស់គាត់ នូវសេចក្តីរន្ធត់តក់ស្លុតលាក់កំបាំងមួយ ដែលបង្ហាញថា ទ្រង់សិរិមតៈកំពុងតែដឹងខ្លួន ថាទ្រង់ធ្លាក់ចូលក្នុងអន្ទាក់របស់គេ ហើយប្រទាញចូលទៅក្នុងការផ្សងព្រេងមួយ ដែលទ្រង់មិនអាចឃើញច្រកចេញ ។ ទ្រង់បានអំពាវនាវដោយមិនចំពោះ ដល់ក្រសួងយោធារបស់ទ្រង់ ឲ្យមានសេចក្តីស្ងប់ស្ងាត់ ឲ្យប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវ«វិន័យនិងករណិយកិច្ចជាធំ» ពីព្រោះទ្រង់មានជំនឿដោយមិនរបេះថា ពួកអ្នកបាញ់យួនបណ្តែតទឹក សុទ្ធសឹងតែជាពួកកូនចៅនៅក្រោមបង្គាប់របស់ទ្រង់ ។ គួរកត់សម្គាល់ថា កាលសម័យនោះ ទ្រង់សិរិមតៈកាន់កាប់កិច្ចការកងទ័ពដោយផ្ទាល់ជាមួយនឹងឧត្តមសេនីយ៍លន់នល់ ។ ប៉ុន្តែតើធ្វើម្តេច ពួកយោធាខ្មែរដែលគ្មានការបង្គាប់បញ្ជាពីចៅហ្វាយនាយ... ដែលកាន់ព្រះពុទ្ធសាសនា, ដែលគ្មានគំរោងទុកជាមុនសោះ ហើយពុំដែលទទួលការហាត់ហ្វឹកហ្វឺននៃការកាប់សម្លាប់មនុស្សទាំងហ្វូងទាំងហ្វាយ មិនត្រឹមតែប៉ុណ្ណោះសោត ពួកគេធ្លាប់តែរស់ដោយសុខស្រួល លាយឡំនឹងប្រជាជនស៊ីវិលថែមទៀត តើធ្វើម្តេចនឹងពួកទាហានខ្មែរ អាចប្រព្រឹត្តការ«ពិឃាតរង្គាល» ដ៏មហាថោក

ទាបជាងសត្វតិរច្ឆានទាំងនេះទៅបាន ? (គឺសម្លាប់ប្រជាជនយួនរាប់ពាន់នាក់ ដោយចងស្លាបសេក ហើយបាញ់ទម្លាក់ទឹក ក្នុងអំពើហឹង្សាមួយ ដែលគ្មានគោលដៅ ឬគ្មានអត្ថន័យអ្វីទាល់តែសោះ) ។ ដើម្បីគេអាចធ្វើការពិឃាតរង្គាលបែបនេះទៅបាន វាទាល់តែរដ្ឋាភិបាលជួយផ្តល់ការពិសោធន៍ហ្វឹកហ្វឺន «ពួកឃាតករ» រាប់ឆ្នាំ យ៉ាងសកម្ម ដូចគេបង្ហាត់បង្រៀនឆ្កែកាច ។ ការបង្ហាត់បង្រៀនក្រុម «កុម្មង់ដូឃាតករ» បែបដូចនេះ វាមានតែនៅខាងជំរំពួកយៀកមិញតែប៉ុណ្ណោះ ។

ដូច្នេះវិប្បដិសារីលាក់កំបាំងរបស់ទ្រង់សិរិមតៈដែលគេអាចមើលឃើញ ផុសចេញមកត្រដែត នៅតាមចន្លោះបន្ទាត់នៃអត្ថបទរបស់គាត់ (Entre les lignes)... គឺជាលទ្ធផលទាំងស្រុងនៃការថ្មិនភ្នែកដ៏ប៉ិនប្រសប់របស់សម្តេចសីហនុ ហើយនិងពួកយួនឈ្លានពាន ។ ពួកកុម្មង់ដូយៀកកុងជាអ្នកបានប្រព្រឹត្តបទឧក្រិដ្ឋ (សម្លាប់ពួកយួនកាតូលិក) ហើយក(ចង្អុលបង្ហាញដល់ពិភពលោកទាំងមូល ដោយរាប់ទាំងពួកទាហានលន់-នល់ខ្លួនឯងថែមទៀត ថាឃាតកម្មនេះជាលទ្ធផលនៃទង្វើឆ្គួតលីលា ហឹង្សាកំណាចឃោរឃៅរបស់ជនជាតិខ្មែរ ។ ពួកក្រោយនេះ ដោយមានលន់-នល់ជាមេក្លោង (យោងតាមការចោទប្រកាន់របស់សីហនុហើយនិងពួកយួន) នៅស្ងៀមៗក៏ធ្លាក់ក្នុងវិកលចរិតនៃការប្រព្រឹត្តអំពើយង់ឃ្នង ដែលគ្មានបានផលប្រយោជន៍ ៖ ការកាប់សម្លាប់យួន ។ ពួកគេលែងចេះគ្រប់គ្រងខ្លួនឯងទៅហើយ ម្ល៉ោះហើយការហៀរហូរចូលមកក្នុងទឹកដីខ្មែរនៃពួកយួនឈ្លានពាន គឺគ្រាន់ជាការឆ្លុះបង្ហាញនូវគោលបំណងរបស់ព្រះជាម្ចាស់តែប៉ុណ្ណោះ ។

គេអាចអានអត្ថបទចោទប្រកាន់ដ៏សែនអយុត្តិធម៌បែបដូចខាងលើ (ថាជនខ្មែរជាពួកមនុស្សឆ្កួត) ដែលមានចុះផ្សាយក្នុងទស្សនាវដ្តីបារាំងខាងឆ្វេងមួយ ទៅលើរបបលន់នល់-សិរិមតៈ ព្រមទាំងទៅលើជនជាតិខ្មែរជាទូទៅផងដែរ ៖ «នៅក្នុងខែមីនា (១៩៧០) , លន់-នល់ហើយនិងសិរិមតៈបានស្រែកអំពាវនាវហៅរកសភាវៈ (instints) ដ៏សែនថោកទាបបំផុតរបស់ជនជាតិខ្មែរ ដើម្បីបំផុសបំផុលទង្វើប្រល័យពូជសាសន៍ (ទៅលើជនជាតិយួនដែលរស់នៅក្នុងប្រទេសកម្ពុជា)» (អត្ថបទដកស្រង់ចេញពី «Jeune Afrique» 6 octobre 1970, par L. Nicaise) ។

មានមិត្តភក្តិខ្មែរកម្ពុជាក្រោមច្រើនគ្នាណាស់ ដែលបានប្រាប់ខ្ញុំថា ការសម្លាប់យួនទាំងនេះ គឺជាទង្វើរបស់ពួកយួនគ្មានវាទៅវិញទេ (ពួកយៀកកុង) ។ ម្យ៉ាងវិញទៀត ខ្ញុំក៏បានអានរបាយការណ៍របស់អ្នកនិពន្ធធំៗ ដែលបានបញ្ជាក់សេចក្តីបែបដូចនេះដែរ... គឺយួនសម្លាប់យួនហើយទម្លាក់ទោសទៅលើជនជាតិខ្មែរ ។ ប៉ុន្តែជាយូរអង្វែងឆ្នាំណាស់ ខ្ញុំមិនដែលមានជំនឿទៅលើរបាយការណ៍ទាំងនេះទេ គឺដោយហេតុថា ទង្វើថ្មិនភ្នែករបស់ស្តេចសីហនុហើយនិងពួកឈ្លានពាន មានប្រសិទ្ធិភាពខ្លាំងពេកណាស់មកលើសតិអារម្មណ៍របស់ខ្ញុំ (ក្នុងប្រការដែលគេមិនអាចជឿបានថា តើស្តេចសីហនុមានរឿងអ្វី បានជាទៅផ្តួលព្រលុំខ្លួនឯង... គេមិនអាចជឿ

បានថា តើពួកយួនត្រូវការអ្វី ទៅសម្លាប់ជនជាតិយួន ដែលជាជាតិសាសន៍ដូចគ្នានោះ ?) ។ តទៅនេះជារបាយការណ៍របស់លោក Jean Morice អំពីពេលបន្ទាប់នៃថ្ងៃទី១៨ មីនា ១៩៧០ ៖

«ទូទាំងប្រទេស (ខ្មែរ), ពួកវៀតណាមកុម្មុយនិស្ត បានដកថយទៅពួននៅក្នុងទីជម្រក ហើយបង្វែរមាត់កាំភ្លើងធំតម្រង់ទៅខាងក្នុងនៃប្រទេសកម្ពុជាវិញ នៅពេលជាមួយគ្នាដែលខាងម្ខាងទៀត (ខាងទឹកដីយួន) ពួកវៀតណាមរដ្ឋការ ហើយនិងពួកកងទ័ពអាមេរិកាំង កំពុងតែពង្រីកពង្រឹងកម្លាំងរបស់ខ្លួន (កកន ៖ ដូច្នេះបន្ទាប់ពីថ្ងៃទី១៨ មីនា ១៩៧០... គេអាចសង្កេតឃើញថា ពួកយៀកកុងនិងពួកវៀតណាមរដ្ឋការមានឧត្តមគតិដូចគ្នា... គឺពួកគេលែងឈ្លោះគ្នា ហើបង្វែរហឹង្សាទៅលើជនជាតិខ្មែរវិញ ។ ការទម្លាក់ស្តេចសីហនុ (ដែលសីហនុបានរៀបចំដោយខ្លួនឯងនេះ) គឺជាសញ្ញាឲ្យពួកយួនទាំងសង្ខាងចូលលុកលុយបំផ្លិចបំផ្លាញប្រទេសកម្ពុជាទេតើ) ។

«ការដឹកជញ្ជូនភស្តុភារ (ស្បៀងនិងគ្រឿងអាវុធ) តាមឡានកាមីញ៉ុង ដែលចាកចេញរាល់ល្ងាច ពីកំពង់ផែភ្នំពេញឆ្ពោះទៅរកកងទ័ពវៀតណាមកុម្មុយនិស្ត, ព្រមទាំងការដឹកចញ្ជូនឥវ៉ាន់ដូចគ្នាតាមកុងវ័រ ដែលមកពីកំពង់សោម ក៏ត្រូវបញ្ចប់ត្រឹមនោះ (កកន ៖ តាំងពីឆ្នាំ១៩៦៣មក ស្តេចសីហនុបានផាក់ជំនួយអាមេរិកាំង ហើយបានយកប្រាក់ចំណូល ដែលបានមកពីការដឹកគ្រាប់ឲ្យយៀកកុង មកចិញ្ចឹមកងទ័ពខ្មែរ និងចិញ្ចឹមសេដ្ឋកិច្ចដ៏ស្តមរីងរៃនៅទីក្រុងភ្នំពេញ ។ ដូច្នេះបន្ទាប់ពី១៨មីនា១៩៧០, រដ្ឋាភិបាលលន់-នល់ដាច់ទាំងចំណូលប្រាក់ចុងក្រោយនេះថែមទៅទៀត ដែលបានមកពីប្រភពកុម្មុយនិស្តចិន... ចំណែកប្រាក់ជំនួយពីស.រ.អា.ក៏នៅតែគ្មានដដែល ។ ក្នុងរយៈពេលបីបួនខែ...គឺជារដ្ឋាភិបាលអាក្រាត រងារកំព្រាឯកា ឥតប្រាក់ចំណូល ឥតមានការគាំពារពីមហាអំណាច ទាំងខាងលិចនិងទាំងខាងកើត ហើយដែលត្រូវប្រឈមមុខនឹងយៀកកុង-យៀកមិញដ៏ច្រើនឥតគណនា ដែលបានទទួលជំនួយកប់ក្តោងពីចិន ហើយនិងសហភាពសូវៀត ។ តើនៅក្នុងស្ថានការណ៍ដាច់ខ្យល់បែបនេះ... រដ្ឋាភិបាលលន់-នល់មានកម្លាំង ឬមានគំនិតឯណាទៅសម្លាប់យួន៥,០០០នាក់បណ្តែតទឹកទន្លេមេគង្គនោះ ? ដូច្នេះបើយើងសម្លឹងមើលឲ្យច្បាស់ មិនមែនកងទ័ពយៀកកុងទេដែលត្រូវដាច់ស្បៀង ព្រោះយៀកកុងបានទទួលជំនួយពីចិនតាមផ្លូវលំហូ-ជីមិញមួយទៀត ។ រដ្ឋាភិបាលដាច់ស្បៀង គឺរដ្ឋាភិបាលអព្យាក្រឹត្យរបស់លន់-នល់ !!!) ។

«ជាលទ្ធផល កងទ័ពកុម្មុយនិស្តក៏ចាប់ផ្តើមបំបែកខ្លួនរាយប៉ាយប្រសេចប្រសាចពាសពេញទឹកដីខ្មែរ ចូលជ្រៅទៅខាងក្នុង (កកន ៖ របាយការណ៍របស់លោក Jean Morice វាផ្ទុយនឹងរបាយការណ៍របស់លោក Kissinger ដែលបានអះអាងថាពួកយៀកកុងរត់តម្រង់ទៅខាងព្រៃនគរ)... ដែលនៅទីនោះ ពួកគេបានដើរប្លន់ប្រជាជន ដែលពួកគេបានជួបប្រទះ ដោយកសាងភេរវកម្ម ។ ពួកអ្នកសារពត៌មានបាន

ផតរូបច្រើនណាស់ បង្ហាញពីក្បាលជនជាតិខ្មែរ ដែលគេកាត់ដោតនឹងចំរឹងឫស្សី (កកន ៖ ពិភពលោកមិនបានផ្ដើលនឹងយួនសម្លាប់ខ្មែរទេ ពីព្រោះអ្នកផងបានជឿសំដីរបស់សីហនុរួចទៅហើយ ដែលចោទកាច់មួលថា លន់-នល់ជាឃាតករសម្លាប់យួន) ។

«ម្យ៉ាងទៀត ពួកភ្នាក់ងារវិទ្ធង្សនា (subversion) កុម្មុយនិស្ត បានដើរជ្រួតជ្រាបគ្រប់ច្រកល្ហកក្នុងទឹកដីខ្មែរ ក្នុងគោលប្រាថ្នាធ្វើការបំបះបំបោរ ។ ពួកនេះបានឆ្លៀតឱកាសនៅថ្ងៃទី១១ និងទី១២ មីនា ធ្វើការពិឃាតរង្គាល ទៅលើប្រជាជនយួន ដែលមិនមែនជាកុម្មុយនិស្តនៅកម្ពុជា... ដើម្បីធ្វើការសម្ពាធន៍ទៅលើពួកជនក្រោយនេះឲ្យចុះចូលជាមួយពួកគេ... ព្រមជាមួយគ្នាធ្វើការឃោសនាបន្ថោកបន្ទាបទៅលើរដ្ឋាភិបាលភ្នំពេញ (លន់នល់-សិរិមតៈ) ។ (Cambodge, du sourire à l'horreur p. 206) ។

★★★ ហើយបន្ទាប់ពីនេះ ជាអត្ថបទមួយទៀតនៅក្នុងសៀវភៅរបស់លោក Jean Morice ដដែល ៖

«ពួកយួនបានត្រូវគេសម្លាប់នៅទីក្រុងភ្នំពេញ និងនៅគ្រប់ច្រកល្ហកនៃប្រទេសកម្ពុជា នៅក្នុងឱកាសបាតុកម្មវាយស្ថានទូតយៀកកុងនិងយៀកណាមខាងជើង (កកន ៖ ដូច្នេះគេអាចមើលឃើញភស្តុតាងជាក់ស្តែងថា ពួកយួនវាដើរសម្លាប់យួនគ្នាវា ដើម្បីទម្លាក់ទោសមកលើរដ្ឋាភិបាលលន់នល់-សិរិមតៈ... ពីព្រោះមានសេចក្តីបញ្ជាក់របស់លោក Jean Morice ដដែលនៅខាងលើថា ពួកយៀកកុងវាបានដើរប្រព្រឹត្តការពិឃាតរង្គាលទៅលើពួកយួនដៃ;មិនមែនកុម្មុយនិស្តនៅថ្ងៃទី១០មីនា...គឺជាការច្បាស់ណាស់ ថ្ងៃទី១១មីនា គឺជាថ្ងៃបាតុកម្មវាយស្ថានទូតយួន ។ ដូច្នេះការសម្លាប់ជនជាតិយួននិងការវាយស្ថានទូតយួននៅថ្ងៃទី១១មីនា... គឺពួកយៀកកុងវាបានគ្រោងទុកជាមុន) ។

«បន្ទាប់ពីមានសេចក្តីអំពាវនាវអំពីរដ្ឋាភិបាលភ្នំពេញ, សភាពការណ៍ក៏បានវិលត្រឡប់មករកសភាពស្ងប់ស្ងាត់វិញអស់មួយរយៈពេល, ប៉ុន្តែការសម្លាប់យួនបានព្រព្រឹត្តឡើងមួយសាទៀត នៅក្នុងឱកាសកំណែនទូទៅ និងការប្រយុទ្ធគ្នាជាលើកដំបូង រវាងកងទ័ពខ្មែរនិងទ័ពវៀតណាមកុម្មុយនិស្ត ។ ពួកអ្នកទទួលរងគ្រោះនៃការពិឃាតរង្គាល មិនអាចរាប់បានត្រឹមត្រូវទេ, វាមានការច្របូកច្របល់រវាងពួកអ្នកស្លាប់ដែលជាយៀកកុង និងពួកយួនសន្តិនិយម ពួកអ្នកប្រកបរបរធ្វើជំនួញ និងពួកអ្នកធ្វើស្រែចំការ ។ គេបានពោលថា មានអ្នកស្លាប់រហូតដល់៥,០០០នាក់ ?» ។ (កកន ៖ ពួកអ្នកសម្លាប់យួនសាទី១ក៏យៀកកុង, ពួកអ្នកសម្លាប់យួនសាទី២ ក៏ជាយៀកកុង ។ លោកឧត្តមសេនីយ៍លន់-នល់ ទើបនឹងប្រកាសកំណែនទូទៅ...លោកមានតែកងទ័ព៣៥,០០០នាក់ ហើយមួយភាគធំសុទ្ធសឹងជាទាហាន២៤ម៉ោងដើម្បីទប់ទល់និងយៀកកុងរាប់សែននាក់... បើតាមរបាយការណ៍គីស៊្សីងគ្នើរ ថាមានរហូ

តដល់ទៅ៣០០,០០០នាក់ ។ តើកងទ័ព២៩ម៉ោងរបស់លន់-នល់មានការពិសោធន៍ឯណាគ្រប់គ្រាន់ ដើម្បីធ្វើការពិឃាតរង្គាលទៅលើកងទ័ពយៀកកុង៣០០,០០០នាក់នោះ ? គឺកងទ័ពយៀកណាមខាងជើងនិងយៀកកុងទៅវិញទេតើ ដែលបានធ្វើការពិឃាតរង្គាលប្រល័យពូជសាសន៍ ទៅលើកងទ័ព២៩ម៉ោងរបស់រដ្ឋាភិបាលលន់នល់-សិរិមតៈ) ។

❑

❑ ❑

★★★ ព្រេងវាសនាចារគួចមករួចទៅហើយ ថាមានសង្គ្រាមកើតឡើងនៅប្រទេសកម្ពុជា (គឺព្រហ្មលិខិតរបស់ជនជាតិយួន) ។ នៅខែមេសា១៩៧០, កងទ័ពត្រឹមត្រូវ (Forces régulières) នៃរដ្ឋាភិបាលរបស់យួនខាងជើង តាងនាមសម្តេចសីហនុបានវាយប្រហារដោយចំហ ទៅលើកងទ័ពរបស់ឧត្តមសេនីយ៍លន់-នល់ មុននឹងមានអន្តរាគមន៍នៃកងទ័ពអាមេរិកាំង។ នៅក្នុងរយៈពេលតែពីរបីខែប៉ុណ្ណោះសោះ ប្រទេសអព្យាក្រិត្យសន្តិនិយមនេះ ដែលកំពុងតែនៅដេកលក់នៅឡើយ ក៏បានក្លាយទៅជាទីរហោស្ថានខ្មោចផ្សារហៅមិនឮ... ចំណែកប្រជាជនខ្មែរត្រូវយួនមកច្រូតកាត់ដូចគេច្រូតស្មៅ ជាមួយនឹងខ្វៅមរណៈ ។ កម្លាំងរស់នៃប្រជាជាតិរបស់យើង (គឺប្រជាជនក្មេងៗកណ្តាលអាយុ ដែលកំពុងប្រកបកិច្ចការងារ) ក៏ត្រូវបានកំទេច, ចំណែកប្រជាជនអ្នកចេះដឹង ក៏ត្រូវបានគេបេះ ។ ប្រទេសកម្ពុជាដែលបានក្លាយទៅជាផេះនេះ មិនមែនជាកម្មសិទ្ធិរបស់ស្តេចសីហនុតែម្នាក់ឯងនោះទេ ប៉ុន្តែជាប្រទេសមួយដែលបានសាងសង់ឡើងវិញដោយលំបាក ក្នុងរយៈកាលសន្តិភាព១០០ឆ្នាំរបស់បារាំង ដែលអនុញ្ញាតឲ្យជនជាតិខ្មែរ គេចរួចពីការបោសសំអាតរបស់ជនជាតិថៃនិងអណ្ណាម ។

ចាប់តាំងពីខែមេសា១៩៨០, ពួកកុម្មុង់ដូឃាតករជំបូងនៃវៀតណាមខាងជើងក៏បានមកដល់ ដោយតាងនាមសង្គ្រាមស៊ីវិល សីហនុ-លន់នល់ ហើយក៏បានធ្វើការពិឃាត (ដោយអារក) គ្មានរើសមុខ ទៅលើប្រជាជនខ្មែរប្រុសស្រីក្មេងចាស់ អ្នករដ្ឋការស៊ីវិល, គ្រូបង្រៀន, ពួកនិស្សិត ។ អំពីឃាតកម្មប្រល័យពូជសាសន៍ដ៏មហាអភ័ព្វនេះ... ប្រហែលជាពួកអ្នកកាសែតបរទេស មិនព្រមលើកយកមកនិយាយជារឿងរហូតទៅ ។ ពួកជនជាតិខ្មែរ ដែលមានលក្ខណៈស្លូតបូតដូចសត្វចៀម ក៏បានប្រែក្លាយទៅជាពួក«ឃាតករ», ចំណែកពួកយួនដែលមានលក្ខណៈឈ្លានពាន, ព្រៃផ្សៃដូចសត្វចចក ក៏បានប្រែក្លាយទៅជាពួក«ជនរងគ្រោះ»ទៅវិញ ។ ពិភពលោកទាំងមូលក៏បានប្រែក្លាយទៅជាពិភពសីលធម៌បះជើងឡើងលើ ។ ប្រហែលតរហូតទៅដល់សន្តិវត្សរ៍ខាងមុខទៀតផង ក៏គ្មាននរណាដឹងអំពីល្បិចកលដ៏សែនជ្រៅរបស់មេធ្មប់ម៉ាគ្គីយ៉ាវែលនិយម... គឺជនយួនផាំ-យ៉ាំងដុង ដែលបានគោរពតាមពាក្យបណ្តាំរបស់អ៊ុងហូ... ហើយដែលបានទាញខ្សែព្រឹត្តិការណ៍នៅកម្ពុជាទាំងអស់ដោ

យដៃខ្លួនឯង (ជាពិសេសគឺទី១១ និងទី១៨ មីនា ១៩៧០) ក្នុងប្រការបង្កើតមហា-អន្តរាយហិនហោចខ្លោចផ្សារនៅកម្ពុជា ដែលអនុញ្ញាតឲ្យពួកជនជាតិយួន លេបត្របាក់ប្រទេសនេះបានយ៉ាងងាយស្រួល ។៚

(អត្ថបទដកស្រង់ចេញពីសៀវភៅ «មាគ៌ានៃមហាអន្តរាយ»)